00648638

E 9/7/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 03 / 2011
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

**ជូនចំពោះ :** មេធាវីការពារ អៀង សារី                កាលបរិច្ឆេទ: ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១១

**ចម្លងជូន :** លោក/លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង និង **Susan LAMB** មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី :** ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ :** **សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសំណើសុំពន្យារពេលដើម្បីដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ**

អង្គជំនុំជម្រះយោងទៅលើសំណើសុំរបស់មេធាវីការពារ អៀង សារី ដែលបានដាក់នៅថ្ងៃ ពុធ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ (ឯកសារE9/7)ដែលបានស្នើសុំពន្យារពេលក្នុងការដាក់នូវការជំទាស់ទៅនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំឱ្យកោះហៅដោយការិយាល័យសហព្រះរាជអាជ្ញា ដែលបញ្ជីនេះត្រូវបានជូនដំណឹងជាភាសាខ្មែរ និងភាសាអង់គ្លេសនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ។ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារ អៀង សារី បានដាក់នូវការជំទាស់ទៅនឹងបញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើសុំឱ្យកោះហៅដោយការិយាល័យសហព្រះរាជអាជ្ញា ដោយបានស្នើសុំដាក់នូវសេចក្តីសន្និដ្ឋានក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលនូវការជូនដំណឹងអំពីការសង្ខេបអំពីគុណសម្បត្តិ និងភាពជំនាញរបស់អ្នកជំនាញនីមួយៗដែលបានស្នើសុំឱ្យកោះហៅដោយការិយាល័យសហព្រះរាជអាជ្ញា (E9/4/9)។ នៅក្នុងសំណើដែលមានឯកសារ E9/4/3/2 និង E9/3/7 មេធាវីការពារ អៀង សារី បានរក្សាសិទ្ធិដើម្បីជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញ ក្រោយពេលដែលមេធាវីបានទទួលនូវឧបសម្ព័ន្ធដែលពាក់ព័ន្ធទាំងអស់ ។ ការិយាល័យសហព្រះរាជអាជ្ញាបានដាក់នូវឧបសម្ព័ន្ធទាំងនេះនៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលមានឯកសារ (E9/13) ។ អនុស្សរណៈនេះចាត់ទុកជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើដែលមានឯកសារ E9/7 ព្រមទាំងសំណើសុំពន្យារពេល[illegible] ឯកសារ E9/4/9 ។

សំណើសុំដែលមានឯកសារ E9/7 ស្នើសុំពន្យារពេលនូវកាលបរិច្ឆេទចុងក្រោយក្នុងការដាក់នូវការជំទាស់ទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើសុំឲ្យកោះហៅដោយការិយាល័យសហព្រះរាជអាជ្ញា ។ នៅក្នុងសំណើមេធាវីបានលើកឡើងថា ការពន្យារពេលនោះគឺមានការចាំបាច់ណាស់ ក្នុងគោលបំណងដើម្បីឲ្យមេធាវីការពារក្តីមាននូវពេលវេលាគ្រប់គ្រាន់ ដើម្បីពិចារណាទៅលើការសង្ខេបនូវគុណសម្បត្តិនិងភាពជំនាញរបស់អ្នកជំនាញនីមួយៗដែលបានស្នើសុំឲ្យកោះហៅ និងការសង្ខេបទៅលើអង្គហេតុដែលសាក្សីនីមួយៗរំពឹងថានឹងមកផ្តល់សក្ខីកម្ម ឬអង្គហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗនឹងមកធ្វើសេចក្តីថ្លែងការណ៍ ។ មេធាវីក៏បានលើកឡើងផងដែរថា ការសង្ខេបរបស់សហព្រះរាជអាជ្ញានឹងត្រូវដាក់រហូតដល់ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ហើយមេធាវីការពារក្តីមាននូវរយៈពេលតែប្រាំថ្ងៃប៉ុណ្ណោះ ក្នុងការពិនិត្យព័ត៌មានដែលពាក់ព័ន្ធមុនពេលដាក់នូវការជំទាស់ ។ អង្គជំនុំជម្រះកត់សម្គាល់ថា សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញភាគច្រើនដែលបានស្នើសុំដោយការិយាល័យសហព្រះរាជអាជ្ញានោះ គឺត្រូវបានគេស្តាប់ចម្លើយរួចហើយនៅក្នុងដំណាក់កាលស៊ើបអង្កេត។ បន្ថែមលើនេះទៀត ការិយាល័យសហព្រះរាជអាជ្ញាបានផ្តល់រួចហើយនូវលេខយោងនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និងលេខយោងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង។ មេធាវីការពារ អៀង សារី បានទទួលនូវការជូនដំណឹងរួចហើយអំពីកាលបរិច្ឆេទចុងក្រោយដែលបានកំណត់ដោយអង្គជំនុំជម្រះចាប់តាំងពីការចេញនូវដីកាបង្គាប់ឲ្យដាក់នូវសម្ភារៈ (ឯកសារ E9) នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ។ ក្រុមមេធាវីការពារ អៀង សារី ក៏អាចចូលមើលសំណុំរឿង និងទទួលបាននូវឯកសារដែលពាក់ព័ន្ធផ្សេងៗទៀងចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតមកម្លេះ ដូច្នេះមិនអាចលើកឡើងថា ខ្លួនមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំនូវការជំទាស់ទៅលើបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបាននោះទេ ។

ទាក់ទងទៅនឹងសំណើសុំដែលមានឯកសារ E9/4/9 អង្គជំនុំជម្រះកត់សម្គាល់ថា ការិយាល័យសហព្រះរាជអាជ្ញាបានដាក់នូវការសង្ខេបអំពីគុណសម្បត្តិ និងភាពជំនាញរបស់អ្នកជំនាញដែលបានស្នើសុំតាមកាលបរិច្ឆេទដែលបានកំណត់ដោយដីការបស់អង្គជំនុំជម្រះ (E9)។

**ហេតុដូច្នេះ** អង្គជំនុំជម្រះសម្រេចបដិសេធសំណើសុំពន្យារពេលទាំងពីរ ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C